គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា

Committee for Free and Fair Elections in Cambodia

ខុមហ្វ្រែល COMFREL

ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១២

# ការប្រមើលមើល ចំពោះការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ នាពេលខាងមុខ

ការប្រកួតប្រជែងសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ២០១៣ ហាក់ដូចជាកាន់តែតានតឹងខ្លាំងឡើង។ គណបក្សសិទ្ធិមនុស្ស និងគណបក្សសមរង្ស៊ី បានរួមបញ្ចូលគ្នាជាគណបក្សថ្មីមួយដែលមានឈ្មោះថា " គណបក្សសង្គ្រោះជាតិ ឬ CNRP" ហើយគណបក្សថ្មីនេះក៏បានចុះឈ្មោះ និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃ។ ការលុបឈ្មោះមេដឹកនាំគណបក្សសមរង្ស៊ី គឺលោក សម រង្ស៊ី ដោយក្រុមប្រឹក្សាសង្កាត់បឹងរាំង ក្រោមលេស ប្រធានគណបក្សជំទាស់ជាទណ្ឌិត បានបង្ហាញពីការរំលោភអំណាចនៃការអនុវត្តច្បាប់របស់ គ.ជ.ប។ សមាសភាព គ.ជ.ប អាណត្តិថ្មីត្រូវបានតែងតាំងដោយមិនខ្វល់ដល់សំណើរបស់គណបក្សនយោបាយមិនកាន់អំណាច ហើយបានដាក់សមាសភាពថ្មីនេះឱ្យស្ថិតក្រោមការរិះគន់ និងមិនមានទំនុកចិត្តពីឯករាជភាពក្នុងការបំពេញមុខងារ។ សំពាធពីសហគមន៍អន្តរជាតិលើការកំណែទម្រង់ការបោះឆ្នោតនៅកម្ពុជា និងការសម្របសម្រួលឱ្យមេដឹកនាំគណបក្សជំទាស់បានត្រឡប់ចូលរួមដំណើរការបោះឆ្នោត។

ច្បាប់ស្តីពីគណបក្សនយោបាយបច្ចុប្បន្នបានបង្កភាពលំបាកដល់គណបក្សថ្មីដែលរួមបញ្ចូលគ្នារវាងគណបក្សជាប់ឆ្នោត។ នៅក្នុងករណីដែលមានការរួមបញ្ចូលគ្នាជាគណបក្សថ្មីមួយ ដោយការរំលាយគណបក្សទាំងពីរ នោះចំនួនអាសនៈរបស់គណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី នឹងត្រូវបាត់បង់អាសនៈសភា និងអាសនៈរបស់មន្ត្រីជាប់ឆ្នោតជាច្រើនទៀតនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាឃុំសង្កាត់។ គណបក្សថ្មីនេះនឹងដឹកនាំដោយមេដឹកនាំគណបក្ស សម រង្ស៊ី គឺលោក សម រង្ស៊ី ត្រូវធ្វើជាប្រធានគណបក្ស ហើយលោក កឹម សុខា ដែលបច្ចុប្បន្នជាអ្នកដឹកនាំគណបក្សសិទ្ធិមនុស្ស ជាអនុប្រធាន។ ទោះបីជាយ៉ាងណា រចនាសម្ព័ន្ធថ្នាក់ក្រោមមិនទាន់បានបង្កើតនៅឡើយទេ។ លើសពីនេះទៀត ភាពមិនច្បាស់លាស់នឹងនៅតែមានប្រសិនបើការចោទប្រកាន់ប្រឆាំងប្រធានគណបក្ស សម រង្ស៊ី នឹងត្រូវបានដកចេញពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣។

លោក សម រង្ស៊ី ត្រូវបានតុលាការកាត់ទោសកំបាំងមុខឱ្យជាប់ពន្ធនាគាររយៈពេល១០ឆ្នាំ ពីបទ បំផ្លាញទ្រព្យសម្បត្តិសាធារណៈ បទញុះញង់ និងបទក្លែងបន្លំឯកសារ។ ក្នុងពេលធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០១២ ដែលមានអ្នកមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីផ្លូវការប្រមាណជាង ៩លាន ៧សែននាក់ ទៅចូលរួមបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ មេដឹកនាំគណបក្សជំទាស់ លោក សម រង្ស៊ី ត្រូវបាន គ.ជ.ប សម្រេចលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០១២នេះ។ ក្នុងសវនាការមួយ ដែលមានមេធាវីតំណាងដើមបណ្តឹង លោក សម រង្ស៊ី និងមេធាវីចុងចម្លើយ តំណាង គ.ជ.ប កាលពីថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១២ នៅទីស្នាក់ការ គ.ជ.ប លោក មាន សាទិ សមាជិក គ.ជ.ប បានលើកយកមាត្រា៣៤ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៥០ នៃច្បាប់បោះឆ្នោត ដែលកំណត់ច្បាស់ថា ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ឬបញ្ជីបេក្ខជន លុះត្រាតែបុគ្គលនោះមិនមានឈ្មោះជាទណ្ឌិត ឬមិនមែនជាអ្នកទោសជាប់ពន្ធនាគារ។ មាត្រាដែលយោងខាងលើ មិនបានប្បញ្ញត្តិជាសំអាងជាក់លាក់ដើម្បីផ្តល់អំណាចដល់ គ.ជ.ប ក្នុងការលុបឈ្មោះអ្នកបោះឆ្នោតដែលមិនមានទោសទាក់ទងនឹងបទល្មើសបោះឆ្នោតឡើយ។ ក្រុមប្រឹក្សា

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**Central Office** : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

**P.O. Box** 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ធម្មនុញ្ញនឹងត្រូវស្នើឱ្យបកស្រាយពីធម្មនុញ្ញភាពនៃមាត្រាទាំងពីរខាងលើ តែជាការអនុវត្តកន្លងមក ក្រុមប្រឹក្សាកំពូលមួយនេះ រក្សាជំហររួមជាមួយនឹង គ.ជ.ប និងរដ្ឋាភិបាល។ បច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកបោះឆ្នោតឆ្នាំ២០១២នេះ គ.ជ.ប បានដឹកនាំការលុបឈ្មោះអ្នកបោះឆ្នោតរាប់សែននាក់ ដែលត្រូវបានគេជឿជាក់ថា អាចនឹងនាំឱ្យមានអ្នកបាត់បង់សិទ្ធិបោះឆ្នោតជាច្រើននាក់ផងដែរ។

នៅក្នុងកិច្ចប្រជុំមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់មួយ រវាងរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិច គឺលោកស្រី ហ៊ីលឡារី រ៉ដហាម គ្លីនតុន (Hillary Rodham Clinton) ជាមួយរដ្ឋមន្ត្រីការបរទេសប្រទេសកម្ពុជា គឺលោក ហោណាំហុង លោកស្រី ហ៊ីលឡារី គ្លីនតុន បានលើកឡើងពីបញ្ហានៃការចូលរួមដោយមានភាពសមស្របមួយចំពោះមជ្ឈដ្ឋាននយោបាយសម្រាប់ឆ្នាំ២០១៣ សំដៅទៅលើបរិយាកាសមិនសូវល្អជុំវិញនេះការកាត់ទោសលោកសម រង្ស៊ី ជាដើម។ ករណីនេះក៏បានទាក់ទាញការចាប់អារម្មណ៍ពីអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លោក ស៊ូរីយ៉ា ស៊ូបេឌី (Surya P. Subedi) ដែលបានសរសេរនៅក្នុងរបាយការណ៍របស់លោកកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ស្តីពីស្ថានភាពសិទ្ធិមនុស្ស ដូចជា ករណីលោក សម រង្ស៊ី ដោយបានស្នើសុំឱ្យមានការដោះស្រាយបញ្ហានយោបាយ ដើម្បីឱ្យអតីតអ្នកតំណាងរាស្ត្ររូបនេះ អាចចូលរួមនៅក្នុងការបោះឆ្នោតនាពេលខាងមុខនេះបាន។ រាជរដ្ឋាភិបាលកម្ពុជាអាចនឹងធ្វើការសម្រុះសម្រួលឱ្យមានដំណោះស្រាយពីបញ្ហានេះ ខណៈពេលដែលនឹងមានការប្រជុំកំពូលអាស៊ានបូក (ASEAN Plus including 7th East Asia Summit and Forums) ជាមួយអ្នកដឹកនាំពីបណ្តាបស្ចឹមប្រទេសនានា រួមបញ្ចូលទាំងប្រធានាធិបតីសហរដ្ឋអាមេរិក នៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០១២នេះ។ សហគមន៍អន្តរជាតិជាប្រទេសម្ចាស់ជំនួយសំខាន់ៗរបស់កម្ពុជា ក៏ចង់ឱ្យមេដឹកនាំគណបក្សជំទាស់ចូលរួមការបោះឆ្នោត។ សមាជិកសភាសហភាពអឺរ៉ុបដែលជាអង្គនីតិប្បញ្ញត្តិដ៏មានអំណាចមួយនៅលើពិភពលោក កាលពីថ្ងៃទី២៦ តុលា ក៏បានទាមទារឱ្យរដ្ឋាភិបាលធ្វើកំណែទម្រង់ការបោះឆ្នោត និងជំរុញឱ្យរដ្ឋាភិបាល និងគណបក្សសង្គ្រោះជាតិសម្រុះសម្រួលផ្នែកនយោបាយដើម្បីអនុញ្ញាតឱ្យគណបក្សជំទាស់ថ្មីនេះអាចចូលរួមការបោះឆ្នោត ប្រកបដោយភាពជឿជាក់។ សមាជិកសភាសហភាពអឺរ៉ុបមានចំនួន ៧៥៤នាក់ តំណាងឱ្យអ្នកបោះឆ្នោតប្រមាណជិត ៤០០លាននាក់ បានថ្កោលទោសការកាត់ទោសផ្នែកនយោបាយប្រឆាំងនឹងលោក ម៉ម សូណង់ដូ និងទាមទារឲ្យដោះលែងជាបន្ទាន់។ ជាថ្មីម្តងទៀត សហភាពអន្តរសភាដែលជាអង្គការនិតិបញ្ញតិដ៏ធំមួយនៅលើពិភពលោក បានចេញសេចក្តីថ្លែការណ៍កាលពីថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១២ នេះ សូមឱ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន យកករណីលោក សម រង្ស៊ី មកដោះស្រាយ ហើយយល់ព្រមឱ្យលោក សម រង្ស៊ី វិលចូលស្រុកដើម្បីបានចូលរួមក្នុងការបោះឆ្នោតជាតិខាងមុខនេះ ។ សហភាពអន្តរសភាបានសំណូមពរឱ្យយកបញ្ហានេះ មកជជែកជាសាធារណៈប្រសើរជាជាងដោះស្រាយតាមប្រព័ន្ធតុលាការ។

ការវិវត្តថ្មីៗនេះ គឺថា លោក ប៉ារ៉ាក់ អូប៉ាម៉ា ដែលទើបជាប់ឆ្នោតប្រធានាធិបតីសហរដ្ឋអាមេរិក បន្តមួយអាណត្តិទៀត ត្រូវបានអញ្ជើញឱ្យមកចូលរួមកិច្ចប្រជុំកំពូលអាស៊ានមួយ ក្នុងខែវិច្ឆិកា ដែលកម្ពុជា ធ្វើជាម្ចាស់ផ្ទះ។ លោក សម រង្ស៊ី រំពឹងទុកថា នឹងប្រើប្រាស់ឱកាសនេះដើម្បីចរចាជាមួយនឹងគណបក្សកាន់អំណាចឱ្យបើកច្រកចូលប្រទេសវិញ។ មន្ត្រីរដ្ឋាភិបាលកម្ពុជា បានប្រកាន់ជំហរដោយមិនទទួលឥទ្ធិពលពីសហគមន៍អន្តរជាតិ ប៉ុន្តែមូលហេតុមួយដែលរដ្ឋាភិបាលអាចកាត់បន្ថយនូវសំពាធពីសហគមអន្តរជាតិ រដ្ឋាភិបាលគួរបើកច្រកឱ្យលោក សម រង្ស៊ី ចូលរួមក្នុងការប្រកួតប្រជែងបោះឆ្នោតជ្រើសតាំងអ្នកតំណាងរាស្ត្រខាងមុខ។

ជាញឹកញាប់ គ.ជ.ប ឧទាហរណ៍ លោក អ៊ឹម សួស្តី ប្រធាន គ.ជ.ប បានមានប្រសាសន៍ក្នុងកិច្ចប្រជុំមួយ នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១២ ថា ទោះបីពុំមានវត្តមានគណបក្សប្រឆាំងចូលរួមការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៣ ក៏

ដោយក៏ការបោះឆ្នោតនឹងប្រព្រឹត្តិទៅជាធម្មតា។ ការបង្ហាញជំហរមិនខ្វាយខ្វល់ពីវត្តមាន ឬកង្វល់របស់គណបក្សជំទាស់ ឬចេញមុខការពារគណបក្សកាន់អំណាច តែងត្រូវបានបង្ហាញជាសាធារណៈដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនេះ ដែលជំរុញឱ្យគណបក្សជំទាស់កាន់តែមិនទុកចិត្តលើស្ថាប័នឯករាជ្យដែលមានភារៈរៀបចំការបោះឆ្នោតជាតិមួយនេះ។

គណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស ធ្លាប់ទាមទារស្នើសុំឱ្យមានការផ្លាស់ប្តូរសមាសភាព ដឹកនាំ គ.ជ.ប ថ្មី ដើម្បីបង្ហាញពីតម្លាភាព និងយុត្តិធម៌នៅក្នុងការរៀបចំការបោះឆ្នោតជាតិ ឆ្នាំ២០១៣ ខាងមុខ។ ការទាមទារឱ្យមានកំណែទម្រង់ការបោះឆ្នោត និងការផ្លាស់ប្តូរសមាសភាព គ.ជ.បថ្មី មានតុល្យភាពនៅគ្រប់លំដាប់ថ្នាក់ ដែលមានការតែងតាំងពីគណបក្សសំខាន់នៅក្នុងរដ្ឋសភា។ កាលពីពេលកន្លងមកក៏មានការលើកឡើងដោយសហគមន៍អន្តរជាតិជាច្រើន។

ទោះបីជាមានសំណើជាច្រើនលើកពីការកំណែទម្រង់សមាសភាព គ.ជ.ប រដ្ឋាភិបាលរបស់គណបក្សប្រជាជនកម្ពុជា ក្រសួងមហាផ្ទៃ និងគណៈរដ្ឋមន្ត្រី បានរក្សាសមាសភាព គ.ជ.ប ដោយប្តូរតែ ពីររូប[1] ហើយដាក់ទៅរដ្ឋសភា កាលពីថ្ងៃទី១១ ខែតុលា ឆ្នាំ២០១២ ប្រជុំអនុម័តគាំទ្រសមាសភាពដដែល របស់ គ.ជ.ប ដោយមានសមាជិកសភាត្រឹម ៨៧រូប ដែលមកពីគណបក្សប្រជាជនកម្ពុជា និងគណបក្សសម្ព័ន្ធភាពរបស់គណបក្សប្រជាជនកម្ពុជា គឺគណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្សជាតិនិយម ខណៈដែលគណបក្សជំទាស់គឺ គណបក្សសមរង្ស៊ី និង គណបក្សសិទ្ធិមនុស្ស បានធ្វើពហិការមិនចូលរួមអង្គប្រជុំដើម្បីបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់សមាសភាព គ.ជ.ប អាណត្តិថ្មីនោះទេក៏ដោយ។

គណបក្សផ្សេងទៀតដែលរួមបញ្ចូលគ្នាសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ នេះត្រូវបានគេប្រកាសឱ្យដឹងថាគឺគណបក្សជាតិនិយម និងគណបក្សហ្វ៊ុនស៊ិនប៉ិច នៅក្រោមគណបក្សហ្វ៊ុនស៊ិនប៉ិចតែមួយ។ ទាំងនេះអាចនឹងនាំឱ្យមានការប្រកួតប្រជែងកាន់តែខ្លាំង និងភាពប្រឈមមួយចំពោះគណបក្សប្រជាជនកម្ពុជា ដែលបច្ចុប្បន្នមានសម្លេងលើសលុប ព្រមទាំងគណបក្សជំទាស់បច្ចុប្បន្នដែលអាចនឹងបាត់បង់សម្លេងឆ្នោតសម្រាប់គណបក្សថ្មីរបស់ពួកគេ។ បើទោះជាមានការប៉ុនប៉ងរួមបញ្ចូលនូវគណបក្សទាំងពីរនេះ ឈានទៅរកការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់បានបរាជ័យ ដោយសារតែមានជម្លោះរវាងសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ ដែលជាប្រធានគណបក្សជាតិនិយម និងឯកឧត្តម ញឹក ប៊ុនឆៃ ជាប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច។ ទោះជាយ៉ាងណា បន្ទាប់ពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់មក អគ្គលេខាធិការគណបក្សជាតិនិយម បានជម្រុញឱ្យមានការរួមបញ្ចូលគ្នាដោយជោគជ័យជាមួយនឹងគណបក្សហ្វ៊ុនស៊ិនប៉ិច ខណៈពេលដែលគណបក្សជាតិនិយម បានប្តូរប្រធានគណបក្ស និងឈ្មោះគណបក្សទៅជា "គណបក្សជាតិនិយម ឬ NP" វិញ។ ម្យ៉ាងវិញទៀតសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ក៏ធ្លាប់បានទទួលការស្នើសុំពីអ្នកដឹកនាំថ្មីរបស់គណបក្សជាតិនិយមឱ្យឈប់ពាក់ព័ន្ធជាមួយរឿងនយោបាយផងដែរ។ មានការចោទប្រកាន់ចំពោះសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ពីគម្រោងធ្វើការងារជាមួយគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សដើម្បីឱ្យការផ្លាស់ប្តូររដ្ឋាភិបាល។ ទំនោររបស់គណបក្សហ្វ៊ុនស៊ិនប៉ិច គឺចង់ចងសម្ព័ន្ធភាពជាមួយគណបក្សប្រជាជនកម្ពុជា ដោយសារតែមិនមានគោលដៅដើម្បីផ្លាស់ប្តូររដ្ឋាភិបាល ក៏ប៉ុន្តែគណបក្សមួយនេះនឹងកាន់តែមានអានុភាពចំពោះការពួតដៃគ្នានាពេលអនាគត។ ការរួមបញ្ចូលជាគណបក្សតែមួយ ដែលបានកើតមាន

[1] តាមព្រះរាជក្រឹត្យ របស់ព្រះមហាក្សត្រ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១២ បានត្រាស់បង្គាប់តែងតាំងសមាសភាព គ.ជ.ប. ចំនួន ៩ រូប រួមមាន៖ ១- លោក អ៊ឹម សួស្តី ជាប្រធាន ២- លោកស្រី ស៊ីន ជុំបូ ជាអនុប្រធាន ៣- លោក ហាវ៉ាណ ស៊ីរិល័យ ជាសមាជិក ៤- លោក មាន សាទិ ជាសមាជិក ៥- លោក ឯម សូផាត ជាសមាជិក ៦- លោក សោម ច័ន្ទឌីណា ជាសមាជិក ៧-លោក ម៉ៅ សុភារិទ្ធ ជាសមាជិក ៨- លោក ស៊ិន ឌឹម ជាសមាជិក និង៩- លោក សោ សុភរី ជាសមាជិក។

ឡើងបន្ទាប់ពីសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានប្រកាសដំណឹងជាសាធារណៈក្នុងខែសីហា ឆ្នាំ២០១២ ថា លាលែងឋានៈជាប្រធានគណបក្ស នរោត្ត មរណឫទ្ធិ និងមិនធ្វើនយោបាយទៀត។

យ៉ាងណាមិញ លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់នឹងជះឥទ្ធិពលដល់លទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៥ ឆ្នាំ២០១៣។ ផ្អែកលើលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ខាងមុខនេះវិញ នឹងមិនមានការផ្លាស់ប្តូរធំដុំ ក្រៅតែពីគណបក្សប្រជាជនកម្ពុជា និងគណបក្សជំទាស់នោះទេ។ ក្នុងករណីដែលគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានរួមបញ្ចូលគ្នាប្រកបដោយជោគជ័យ ពួកគេអាចទទួលបានសម្លេងឆ្នោតកើនឡើងដល់ទៅ ៣០ ភាគរយនៃសន្លឹកឆ្នោត ហើយអាចកើនឡើងនៃចំនួនអាសនៈដល់ ៣៦ អាសនៈ (ក្នុងឆ្នាំ២០០៨ ទទួលបាន ២៩ អាសនៈ)។ នៅពេលបច្ចុប្បន្ននេះគណបក្ស សម រង្ស៊ី កាន់កាប់ចំនួនអាសនៈតែ ២៦ អាសនៈ (២២ភាគរយនៃសន្លឹកឆ្នោតសរុប) ហើយគណបក្សសិទ្ធិមនុស្ស កាន់កាប់ចំនួន ៣ អាសនៈ (៦ ភាគរយ នៃសន្លឹកឆ្នោត) នៅក្នុងសភា។ នៅពេលដែល គណបក្សសិទ្ធិមនុស្ស បានកើនឡើងនូវសម្លេងឆ្នោតសរុប នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០១២ ដល់ទៅ ១០ភាគរយ បើប្រៀបធៀបទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។ ទោះបីជាយ៉ាងណា គណបក្សប្រជាជនកម្ពុជា អាចរក្សាសន្លឹកឆ្នោតដដែល ប៉ុន្តែអាចនឹងបាត់បង់អាសនៈខ្លះទៅគណបក្សដទៃសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ ដែលក្នុងនោះគណបក្សប្រជាជនកម្ពុជាអាចនឹងទទួលបានត្រឹម ៨៦អាសនៈ ជំនួសឱ្យ ៩០អាសនៈដែលបានឈ្នះនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨។

ផ្ទុយទៅវិញ ក្នុងករណីដែលគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្សបរាជ័យក្នុងការរួបរួមគ្នា នោះគណបក្សគណបក្ស សម រង្ស៊ី អាចនឹងបាត់បង់អាសនៈសភា ទៅឱ្យគណបក្សសិទ្ធិមនុស្ស និងគណបក្សប្រជាជនកម្ពុជា ខណៈពេលដែលគណបក្សសិទ្ធិមនុស្សអាចកើនឡើងនូវសម្លេងឆ្នោតប្រហែលជា ៤ភាគរយ បើប្រៀបធៀបទៅនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ ផងដែរ។ លទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់បានបង្ហាញថា គណបក្ស សម រង្ស៊ី បានបាត់បង់សម្លេងឆ្នោត។ ចំនួនអាសនៈរបស់គណបក្សសមរង្ស៊ី នឹងមានការថយចុះទៅឱ្យគណបក្សសិទ្ធិមនុស្ស និងគណបក្សប្រជាជនកម្ពុជា ដែលអាចនឹងទទួលបាន ២អាសនៈបន្ថែមទៀតក្នុងគណបក្សនិមួយៗទៅលើអាសនៈដែលមាននៅក្នុងរដ្ឋសភាបច្ចុប្បន្ន។

គណបក្សជាតិនិយម និងគណបក្សហ៊្វុនស៊ិនប៉ិច នឹងមិនរំពឹងថាទទួលបាននូវការកើនឡើងធំដុំទេបើផ្តោតលើលទ្ធផលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយគណបក្សទាំងពីរនេះអាចរក្សាបានអាសនៈ២ ខណៈដែលបាត់បង់អាសនៈរបស់ខ្លួនបច្ចុប្បន្នដល់ទៅ២អាសនៈនៅក្នុងសភា (អាសនៈរបស់គណបក្សទាំងពីរនេះមាន៤អាសនៈក្នុងឆ្នាំ២០០៨)។ សម្លេងឆ្នោតរបស់ពួកគេបានថយចុះគួរឱ្យកត់សម្គាល់នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់។ យ៉ាងណាក៏ដោយ ចំពោះការស្មានទុកជាមុននៃទិន្នផលបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ទាំងនេះមិនអាចផ្តល់ជាការទទួលយកបាន ចាប់តាំងពីគំរូភាពនៃអ្នកបោះឆ្នោតដែលអាចនឹងមានភាពខុសគ្នានៅកំឡុងពេលបោះឆ្នោតសភា។ ការចាប់អារម្មណ៍របស់អ្នកបោះឆ្នោតក្នុងការបោះឆ្នោតឱ្យគណបក្សនយោបាយនៅក្នុងការដឹកនាំក្រុមប្រឹក្សាឃុំ-សង្កាត់ខុសពីការបោះឆ្នោតជ្រើសរើសគណបក្សជាអ្នកតំណាងរាស្ត្រ។

លទ្ធផលការបោះឆ្នោតសម្រាប់ការបោះឆ្នោតព្រឹទ្ធសភាអាណត្តិក្រោយ និងការបោះឆ្នោតក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ (ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ) អាចត្រូវបានគណនាចេញពីសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងសមាជិកសភាតំណាងឱ្យប្រជាពលរដ្ឋដែលជាអង្គបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។ វិន័យរបស់គណបក្សនយោបាយគឺមានភាពតឹងរឹងសំរាប់គណបក្សនយោបាយក្នុងប្រទេសកម្ពុជា ហើយវាអាចត្រូវបានគេរំពឹងទុកថា អង្គបោះឆ្នោតនឹងត្រូវបានធ្វើឡើងតាមបញ្ជារបស់គណបក្ស។ បេក្ខជនឯករាជ្យ គឺមិនត្រូវបានអនុញ្ញាតនៅក្នុងការបោះ

ឆ្នោតនេះទេ។ ហេតុដូច្នេះហើយ ពឹងផ្អែកទៅលើលទ្ធផលបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ឆ្នាំ២០១២ និងសន្មត់ថា គណបក្សប្រជាជនកម្ពុជាអាចកាន់កាប់អាសនៈនៅក្នុងសភារបស់ខ្លួនសម្រាប់ឆ្នាំ២០១៣មានចំនួនថយចុះ ២អាសនៈ ដែលក្នុងនោះថយពី ៤៦ អាសនៈមក ៤៤អាសនៈ ឬថយមកត្រឹម ៨០ភាគរយ (បច្ចុប្បន្នគណបក្សប្រជាជនកម្ពុជា កាន់កាប់ច្រើនជាង ៨០ភាគរយ ឬ៤៦អាសនៈ នៃចំនួនអាសនៈព្រឹទ្ធសភាសរុប ៥៧អាសនៈ) ដែលនៅក្រោមការ ត្រួតត្រា និងបន្តកាន់កាប់ដោយប្រព័ន្ធគណបក្សកាន់អំណាចតែមួយ។ គណបក្ស សម រង្ស៊ី និង/ឬគណបក្សសិទ្ធិ មនុស្សអាចនឹងទទួលបានចំនួនអាសនៈក្នុងព្រឹទ្ធសភាដែលកើនឡើងចំនួន ២អាសនៈ កើនពី ១១អាសនៈ ទៅ ១៣ អាសនៈ (បច្ចុប្បន្ន គណបក្ស សម រង្ស៊ី និង/ឬគណបក្សសិទ្ធិមនុស្សកាន់កាន់ប្រមាណ ១៩ភាគរយ នៃចំនួនអាសនៈ ព្រឹទ្ធសភាសរុប ៥៧អាសនៈ)។ ដូចគ្នាដែរ ការបោះឆ្នោតអសកល ក្នុងការជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ គណបក្សប្រជាជនកម្ពុជានឹងអាចទទួលបាន ៧៩ភាគរយនៃអាសនៈថ្នាក់ក្រោមជាតិ ខណៈពេល ដែលគណបក្ស សម រង្ស៊ី និងគណបក្សសិទ្ធិមនុស្ស នឹងអាចទទួលបាន ២១ភាគរយនៃអាសនៈសរុបក្រុមប្រឹក្សាថ្នាក់ ក្រោមជាតិ។ គណបក្សជាតិនិយម ឬ/និងគណបក្សហ៊្វុនស៊ិនប៉ិចនឹងទទួលបានតិចជាង ១ភាគរយនៃចំនួនអាសនៈ ក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ។ ចំនួនអាសនៈសរុបសំរាប់អាសនៈក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងក្រុមប្រឹក្សា រាជធានី/ខេត្ត ក្រុង ស្រុក/ខណ្ឌ គឺ ៣២៣៥អាសនៈ ។

សរុបមកវិញ លទ្ធផលបោះឆ្នោតខាងមុខអាចមានការថយចុះតិចតួចរបស់គណបក្សប្រជាជនកម្ពុជាសំរាប់ អាសនៈព្រឹទ្ធសភា ក្រុមប្រឹក្សាខេត្ត/ស្រុក/រាជធានី និងសមាជិកសភា រីឯគណបក្សសង្គ្រោះជាតិ (CNRP) ឬគណបក្ស សមរង្ស៊ី និងគណបក្សសិទ្ធិមនុស្ស(ក្នុងករណីការរួបរួមគ្នាបានជោគជ័យមុនការបោះឆ្នោត) នឹងមានការកើនឡើងតិច តួចចំនួនសមាជិកសភា និងក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ។ ផ្ទុយទៅវិញ គណបក្សហ៊្វុនស៊ិនប៉ិច និង/ឬគណបក្សជាតិ និយម អាចនឹងបាត់បង់អាសនៈដ៏ច្រើនរបស់ខ្លួនសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៥។ ប៉ុន្តែ លទ្ធផលសន្លឹកឆ្នោតខាងមុខក៏អាចប្រែប្រួលខ្លះថែមទៀត នៅពេលអ្នកមិនបានបោះឆ្នោតនៅឆ្នាំ២០១២ និងអ្នកចុះ ឈ្មោះបោះឆ្នោតថ្មី ប្រមាណ ៣លាន ៥សែន នាក់ ចេញមកបោះឆ្នោតក្នុងនោះជាង ៥០% ដែលបាត់បង់ទឹកចិត្តរឿង បញ្ហានយោបាយ។ ការបោះឆ្នោតខាងមុខ អាចលេចចេញតែក្រុមគណបក្សនយោបាយប្រកួតប្រជែងពីរ លេចធ្លោ គឺ គណបក្សប្រជាជនកម្ពុជា និងគណបក្សជំទាស់ គណបក្សសង្គ្រោះជាតិ។ បរិយាកាស និងដំណើរការបោះឆ្នោត អាច នៅបន្តមានបញ្ហាមិនទាន់សេរី យុត្តិធម៌ និងតម្លាភាពពេញលេញដដែល។ ភាពជឿជាក់ និងនីត្យានុកូលភាពនៃលទ្ធ ផលបោះឆ្នោតលើកនេះ ក៏នឹងធ្លាក់ចុះយ៉ាងខ្លាំង ដោយសារគ្មានការចូលរួមពេញលេញ ពីគណបក្សជំទាស់ក្នុងការ រៀបចំ និងត្រួតពិនិត្យការជ្រើសរើសសមាសភាព គ.ជ.ប គ្រប់លំដាប់ថ្នាក់ មេដឹកនាំគណបក្សជំទាស់មិនអាចឈរ ឈ្មោះបោះឆ្នោត និងដឹកនាំគាំទ្រគណបក្សខ្លួនក្នុងការប្រកួតប្រជែងបោះឆ្នោតនេះផ្ទាល់នៅក្នុងប្រទេសបានទេ៕

**បេសកម្ម** ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោត ដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះ ឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំ ទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុង កិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការ វាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួកទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។